# កូនខ្មែរចាំបាច់ត្រូវតែដឹង




**ស៊ាន បេ៉ងសែ**

វិស្វកររ៉ែ
អតីតរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង សិប្បកម្ម
ប្រធាន គណៈកម្មាធិការព្រំដែនកម្ពុជា

បោះពុម្ពលើកទី ២ - វិច្ឆិកា ២០០៤

រៀបចំបោះពុម្ពផ្សាយដោយ
គណៈកម្មាធិការព្រំដែនកម្ពុជា

# មាតិការឿង

## រឿងដែលកូនខ្មែរចាំបាច់ត្រូវ ដឹងអំពីបូរណភាពទឹកដីខ្មែរ


ទំព័រ

សន្និសញ្ញាក្រុងហ្សឺណែវ (ប្រទេសស្វីស) ស្តីពីបញ្ហា ឥណ្ឌូចិន ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ១៩៥៣ .... ៤

គណៈកម្មការចំរុះ និងគណៈកម្មការអន្តរជាតិ ដើម្បីឃ្លាំមើល និងត្រួតពិនិត្យលើប្រទេស កម្ពុជា .................. ៤

ការចូលលុកលុយ និងកាន់កាប់ប្រទេសកម្ពុជា ដោយវៀតណាម នៅថ្ងៃទី ៧ មករា ១៩៧៩ ........................ ៧

រដ្ឋាភិបាលក្បាលពីរ ១៩៩៣ និង រដ្ឋាភិបាល ចំរុះ ប្រជាជន និង ហ្វុនសិនប៉ិច (១៩៩៩-២០០៣) .. ១២

រដ្ឋាភិបាលកញ្ចប់ ២០០៤ .............................. ១៣

អត្ថបទរបស់ព្រះករុណា នរោត្តម សីហនុ ........... ១៦

# រឿងដែលយុវជនខ្មែរចាំបាច់ត្រូវ ដឹងអំពីបូរណភាពទឹកដីខ្មែរ

(រៀបរៀងដោយ ស៊ានប៉េងសែ ថ្ងៃទី ៩ កញ្ញា ២០០៣)

## សន្ធិសញ្ញាក្រុងហ្សឺណែវ (ប្រទេសស្វីស) ស្តីពីបញ្ហាឥណ្ឌូចិន ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ១៩៥៤

-សេចក្តីថ្លែងការណ៍បញ្ចប់នៃសន្និសិទក្រុងស្វីណែវស្តីពីការ នាំមកវិញនូវសន្តិភាពក្នុងឥណ្ឌូចិន ។

ប្រការ ១២ - ក្នុងការទំនាក់ទំនងជាមួយកម្ពុជា លាវនិងវៀតណាម ប្រទេសនិមួយៗដែលបានមកចូល រួមក្នុងសន្និសិទក្រុងស្វីណែវ ប្តេជ្ញាគោរពអធិបតេយ្យភាពឯករាជ្យភាព ឯកភាព និងបូរណភាពទឹកដី និង ជៀសវាងមិនជ្រៀតជ្រែកផ្ទៃក្នុងនៃប្រទេសខាងលើនេះ ។

## គណៈកម្មការចំរុះ និងគណៈកម្មការអន្តរជាតិ ដើម្បីឃ្លាំមើលនិងត្រួតពិនិត្យលើប្រទេស កម្ពុជា

ប្រការ ១១ - គណៈកម្មការអន្តរជាតិមានភារៈឃ្លាំមើល និងត្រួតត្រាក្នុងការអនុវត្តន៍លើបទបញ្ញត្តិនៃការ សំរេចលើការបញ្ចប់ចំបាំងនៅកម្ពុជា ។ គណៈកម្មការនេះមានអ្នកតំណាងពីប្រទេសកាណាដា ឥណ្ឌា និង ប៉ូឡូញ ។ គណៈកម្មការស្ថិតនៅក្រោមតំណាងប្រទេសឥណ្ឌាជាប្រធាន និងមានទីស្នាក់ការនៅក្រុងភ្នំពេញ។

ប្រការ ១៣ - គណៈកម្មការអន្តរជាតិមានភារៈឃ្លាំមើលលើហត្ថលេខីទាំងអស់ក្នុងការ ប្រតិបត្តិ នៃបទ បញ្ញត្តិរបស់សេចក្តីសំរេច ។ ក្នុងន័យនេះ គណៈកម្មការបំពេញបេសកកម្មក្នុងការត្រួតត្រា ការសង្កេត ការ ត្រួតពិនិត្យនិងការស៊ើបអង្កេតលើអ្វីៗដែលទាក់ទងនិងការអនុវត្តន៍លើបទបញ្ញត្តិនៃសេចក្តីសំរេចអំពីការបញ្ចប់ចំបាំងដូចជា ៖

ក) ត្រួតត្រាក្នុងការដកចេញរបស់ទាហ៊ានបរទេស ឱ្យស្របទៅលើបទបញ្ញត្តិនៃសេចក្តីសំរេចលើការ
បញ្ចប់សង្គ្រាម ហើយនិងត្រួតពិនិត្យក្នុងការគោរពនូវព្រំដែនទាំងអស់។

ខ)ត្រួតត្រាក្នុងប្រតិបត្តិការរំដោះអ្នកជាប់ទោសជាអ្នកធ្វើសង្គ្រាម និង អ្នកជាប់ទោស ជាស៊ីវិល។

គ) ឃ្លាំមើលនៅតាមកំពង់ផែ តាមចំណតយន្តហោះ និងនៅតាមព្រំដែនទាំងអស់នៃប្រទេស កម្ពុជា ក្នុងការអនុវត្តន៍នៃសេចក្ដីប្រកាសរបស់ខ្មែរអំពីរឿងជំនួយបរទេស ជាបុគ្គលិកទាហាននិងជាសព្វាវុធ ចំបាំង។

សូមរំលឹកថាក្នុងពេលនោះ ពួក « បូដូយ » ជាច្រើនពាន់ច្រើនម៉ឺននាក់ ដែល គេតែងហៅថា « វៀតមិញ » ក្រោយពីបានដកខ្លួនថយទៅ បានទៅវាយបណ្ដាក់គ្នានិងកាន់កាប់តំបន់ ជាច្រើន នៃ ប្រទេសកម្ពុជា ដោយបានកេណ្ឌទៅជាមួយផងទៅក្នុងតំបន់ទាំងនោះ នូវយុវជនខ្មែរ ដែលគេ ខិតខំ បង្ហាត់បង្រៀន សាបព្រោះមនោគមន៏វិជ្ជារបស់គេ និងហ្វឹកហ្វឺនខាងយុទ្ធវិធី ។

ចំណែកឯខាងហាណូយឯណោះវិញ យុវជនខ្មែរដទៃទៀតកំពុងបញ្ចប់ការហ្វឹកហ្វឺនរបស់គេ ដើម្បី បំពេញបេសកកម្មនាពេលខាងមុខនៅក្នុងប្រទេសកម្ពុជា ស្រប ទៅតាមគំរោងការណ៍ដែលប្រទេស វៀតណាមគេបានគ្រោងទុកមកជាយូរមក ហើយ។ គឺពួកនេះហើយដែលបានចូលដៃយ៉ាង សកម្ម ក្នុងការចូល មកវាយលុករុករានប្រទេសកម្ពុជារបស់ខ្លួន នៅក្នុងឆ្នាំ ១៩៧៩ ។

I-ការទទួលស្គាល់ជាច្រើនលើកច្រើនគ្រាពីសំណាក់ប្រទេសវៀតណាម នូវបូរណភាពទឹកដីរបស់ ប្រទេសកម្ពុជានៅក្នុងព្រំដែនឆ្នាំ ១៩៥៤ លើកទី ១ គឺ នៅថ្ងៃទី ២០ ខែសីហា ឆ្នាំ១៩៦២ ជាមួយ និងប្រទេសនានាទៀតដូចជាប្រទេសបារាំងប្រទេសចិននិងសហភាពសូវៀត ។ល។ បន្ទាប់ពីសន្ធិ-សិទក្រុងស៊្មីណែវ ឆ្នាំ១៩៥៤ មក ។

II-សេចក្ដីប្រកាសរបស់លោក ផាំវ៉ាន់ដុង ស្ដីពីព្រំដែនរវាងប្រទេសកម្ពុជានិងវៀតណាម នៅពេល ប្រជុំលើកទី១នៃសភាជាតិ(វៀតណាម) និតិបញ្ញត្តិទី៣ ពីថ្ងៃទី២៧ ខែមិថុនា ដល់ថ្ងៃទី៣ ខែកក្កដា ឆ្នាំ១៩៦៤ នៅទីក្រុងហាណូយ។

ប្រជាជនវៀតណាមនិងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមគាំទ្រដាច់ខាតនូវសំ-ណើររបស់សម្ដេចព្រះ នរោត្តមសីហនុ ប្រមុខរដ្ឋប្រទេសកម្ពុជា (ស្ដីអំពីការគាស់ហៅសន្ធិសិទ ស្ជីណែវមួយរវាងប្រទេសទាំង១៤ ដើម្បីគោរពនិងធានាដល់អព្យាក្រឹតភាពរបស់ប្រទេសកម្ពុជា)។

ប្រជាជន វៀតណាម និង រដ្ឋាភិបាល សាធារណរដ្ឋ ប្រជាធិបតេយ្យវៀតណាម យល់ព្រមទាំងស្រុងលើ សេចក្តីប្រកាស(ខាងក្រោមនេះ)របស់រណសិរ្សរំដោះជាតិ (FNL) ស្តីពីព្រំដែនកម្ពុជា-វៀតណាម ខាងត្បូង និង កោះទាំងអស់ នៅមុខក្រុងកែប ៖

"យើងគោរពព្រំដែនបច្ចុប្បន្ន ដែលបានកំណត់តាំងដើមមក (ដែលបានកំណត់តាំងពីយូរយារមកហើយ)។ នេះជាសក្ខីភាពដែលបង្ហាញថា គ្មានទំនាស់អ្វីបានកើតមានទេ ថ្វីបើតំបន់ដែលបានរំដោះរួចនោះ ជាប់និងព្រំដែនរវាងប្រទេសទាំងពីរ"។ (ហេតុនេះហើយទើបឧប្បត្តិហេតុផ្សេងៗ ពុំដែលមានកើតឡើងនោះទេទោះបីតំបន់ដែលយើងបានរំដោះរួចមកហើយនោះមានព្រំប្រទល់ជាប់ នឹងព្រំប្រទល់របស់ប្រទេសកម្ពុជាក៏ដោយ)។ "ជាពិសេសយើងមិនដែលមានបំណងទាមទារកោះទាំង ឡាយដែលស្ថិតនៅមុខក្រុងកែបនោះទេ ព្រោះយើងយល់ថាកោះទាំងនោះជាកោះរបស់ខ្មែរដែល ឥតប្រកែកបាន"។

ទោះជាយ៉ាងនេះហើយក៏ដោយ ការទទួលស្គាល់របស់រណសិរ្សនេះមិនគ្រប់គ្រាន់នៅឡើយទេ គឺនៅ ខ្វះការទទួលស្គាល់ពីសំណាក់រដ្ឋាភិបាលបណ្តោះអាសន្នវៀតណាមខាងត្បូង ។

ដូចនេះហើយទើបក្រោយពីបានជួបគ្នានៅថ្ងៃ ២៩ ខែកញ្ញា ឆ្នាំ ១៩៦៤ នៅក្រុងប៉េកាំង រវាងសម្តេច នរោត្តម សីហនុ ប្រមុខរដ្ឋខ្មែរ និងលោក ផាំវ៉ាន់ដុង រដ្ឋមន្ត្រីទី ១ នៃសាធារណរដ្ឋប្រជាធិបតេយ្យ វៀតណាមមក មានការចរចារគ្នាមួយទៀតក្នុងខែវិច្ឆិកា ១៩៦៤ ដដែល រវាងសាធារណរដ្ឋ ប្រជាធិបតេយ្យវៀតណាម និងរណសិរ្សវៀតណាមខាងត្បូង ដើម្បីសំរេចពីការទទួលស្គាល់ព្រំដែន កម្ពុជា។

វៀតណាមខាងជើងនិងវៀតណាមខាងត្បូង បានសំរេចចិត្តថានិងទទួលយល់ព្រមតាមសំណើររបស់ ប្រទេសកម្ពុជា ។

ប៉ុន្តែប្រតិភូខ្មែរបានបន្ថែមវិធានបទមួយថ្មីទៀត ដែលប្រជាជនខ្មែរមិនអាចបំភ្លេចបាន គឺការទទួល ស្គាល់សិទ្ធិសំខាន់បំផុតនៃប្រជាជនខ្មែរដែលរស់នៅក្នុងកម្ពុជាក្រោម។ ដំណោះស្រាយនេះក៏ត្រូវខកខានទៅវិញ។

III–ចាប់តាំងពី ខែកញ្ញា ឆ្នាំ១៩៦៦ មក មានការជួបគ្នាជាញឹកញាប់រវាងគណៈប្រតិភូ

ខ្មែរ និង គណៈប្រតិភូរណៈសិរ្សរំដោះជាតិវៀតណាមខាងត្បូង ដឹកនាំដោយលោក សីនសាន និងលោក ត្រាន់ប៊ូគៀម។

IV-សេចក្តីប្រកាសរបស់រដ្ឋាភិបាល សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមនៅថ្ងៃទី ៨ មិថុនា ឆ្នាំ ១៩៦៧ ៖

១-ទទួលស្គាល់និងសន្យាគោរពនូវឯករាជ្យភាព អធិបតេយ្យភាព អព្យាក្រឹតភាព និងបូរណភាព ទឹកដីរបស់ប្រទេសកម្ពុជានៅក្នុងព្រំដែនបច្ចុប្បន្ន ។

២-យល់ព្រមជាដាច់ខាតតាមសេចក្តីប្រកាសរួមចុះថ្ងៃទី ៣១ ខែឧសភា ១៩៦៧ នៃ គណៈកម្មាធិការ កណ្តាលរបស់រណសិរ្សរំដោះជាតិវៀតណាមខាងត្បូង និង កម្ពុជា។

រដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម បានទទួលស្គាល់ និងសន្យា ថាគោរពនូវព្រំដែនទាំងអស់នោះ ។ តែនេះគ្រាន់ជាសំដីដែលគ្មាន ន័យ ប៉ុណ្ណោះ ដោយក្នុងពេលសង្គ្រាមតទល់ ជាមួយ សហរដ្ឋអាមេរិក សាធារណរដ្ឋប្រជាធិប-តេយ្យវៀតណាម និង រណសិរ្សរំដោះជាតិ វៀតណាមខាងត្បូង នៅក្នុងអំឡុងឆ្នាំ ១៩៦០ បានចូលមក កាន់កាប់ភូមិភាគ ជាច្រើននៃប្រទេសកម្ពុជា ដោយនរណាក៏នៅចាំបាន ដែរអំពី « ផ្លូវលុំហូជីមិញ » ដែលបានតភ្ជាប់ចាប់តាំងពីវៀតណាមខាងជើង រហូតមកដល់វៀតណាមខាងត្បូង ដោយកាត់តាមប្រទេសកម្ពុជា ។

## ការចូលមកលុកលុយនិងកាន់កាប់ប្រទេសកម្ពុជាដោយវៀតណាម នៅថ្ងៃទី ៧ ខែមករា ឆ្នាំ ១៩៧៩

V-ប៉ុន្តែឆ្លៀតពេលដែលប្រទេសវៀតណាមខាងជើងនិងខាងត្បូងបានរួមគ្នាមកវិញជាប្រទេសតែមួយ ហៅថាសាធារណរដ្ឋសង្គមនិយមវៀតណាម នៅក្នុង ខែឧសភា ឆ្នាំ ១៩៧៥ ប្រទេសនេះបានចូលមក វាយលុក ហើយកាន់កាប់ប្រទេសកម្ពុជានៅថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ បំភ្លេចចោលទាំងអស់នូវកិច្ច ព្រមព្រៀងទាំងឡាយដែលវៀតណាមបានធ្វើជាមួយនឹងប្រទេសកម្ពុជាពីពេលមុនមក។ មិនត្រឹមតែប៉ុណ្ណោះ ប្រទេសវៀតណាមបានខិតខំគ្រប់បែបយ៉ាងដើម្បីជួយឱ្យរដ្ឋាភិបាល "អាយ៉ង" ដែលវៀតណាមបានតែងតាំងក្នុងពេលដែលកម្ពុជាត្រូវបានកាន់កាប់ដោយវៀតណាមនោះ ឱ្យបាន ស្ថិតស្ថេរជាស្ថាពរ ជាឧបករណ៍មួយសំរាប់អនុវត្តន៍កិច្ចព្រមព្រៀង

ទាំងអស់ (ដែលរដ្ឋាភិបាលសា-ធារណរដ្ឋសង្គមនិយមវៀតណាមបង្ខំឱ្យ រដ្ឋាភិបាល "អាយ៉ង" ខ្មែរនេះចុះជាមួយខ្លួន ជាកិច្ចព្រមព្រៀង) ដែលផ្ទុយនិងច្បាប់ ហើយដែល មានដូចតទៅនេះ ៖

១-សន្ធិសញ្ញាចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ១៩៧៩ ស្តីពី "សន្តិភាព មិត្តភាព និងសហប្រតិបត្តិការ" មានរយៈ ២៥ ឆ្នាំ និងបន្តជាស្វ័យប្រវត្ត (ក្នុងរយៈ ១០ ឆ្នាំម្តងៗ) បើគូភាគីណាមួយមិនបានប្រាប់គូ ភាគីមួយទៀតឱ្យបានដឹង ដោយលាយលក្ខណ៍អក្សរ នូវបំណងរបស់ខ្លួនចង់លុបចោលសន្ធិសញ្ញានេះ ឱ្យបានមុនដំណាច់ កាលបរិច្ឆេតរបស់វានោះទេ។

២-កិច្ចព្រមព្រៀងស្តីពី "តំបន់ទឹកប្រវត្តិសាស្រ្ត" ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៨២ ជាសន្ធិសញ្ញា ដែលបានប្រគល់ទៅឱ្យវៀតណាមផ្តាច់មុខ ជាស្ថាពរ នូវ "កោះត្រល់" ផង "ក្រុមកោះក្រចកសេះ" ផង (Poulo Panjang) ហើយព្រមទាំងបានបង្កើត តំបន់មួយទៀត ឱ្យឈ្មោះថា "តំបន់ទឹកប្រវត្តិសាស្រ្ត" មានទំហំ ១០.០០០គម២ ដាក់នៅក្រោមការត្រួតត្រារួម របស់ប្រទេសទាំងពីរ។ តំបន់ដែល បង្កើតថ្មីនេះស្ថិតនៅក្រោយកោះត្រល់។

ប្រទេសសិង្ហបូរីបានជំទាស់ហើយបដិសេធចោលជាដាច់ខាតនូវកិច្ចព្រម-ព្រៀងនេះ។

គឺដោយសារកិច្ចព្រមព្រៀងនេះ ហើយទើបប្រទេសថៃឡង់ និង វៀតណាម បានចុះហត្ថលេខា លើសន្ធិ-សញ្ញា ផ្សេងមួយទៀត រវាងប្រទេសគេទាំងពីរ ដើម្បីកំរិតព្រំដែនសមុទ្ររបស់គេរៀងៗខ្លួន នៅលើផ្ទៃសមុទ្រខ្មែរ គឺកិច្ចព្រមព្រៀងចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ១៩៩៧ ដែលនាំឱ្យខ្មែរបាត់ដែនសមុទ្ររបស់ ខ្លួនអស់ជាច្រើន ។

៣-សន្ធិសញ្ញាស្តីពី "គោលការណ៍ដើម្បីដំណោះស្រាយព្រំដែន" ចុះនៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៨៣ ដើម្បីកំណត់ព្រំដែនគោកសារជាថ្មី និងកិច្ចព្រមព្រៀងស្តីពី "លក្ខន្តិកៈព្រំដែន" នៅពេលជាមួយគ្នានោះដែរ ដើម្បីបើក ផ្លូវចេញចូល នៅតាមព្រំប្រទល់ដែន ជាជំនួយគមនាគមន៍ ដល់ប្រជាពលរដ្ឋទាំងពីរ។

៤-សន្ធិសញ្ញាស្តីពី "ការកំណត់ព្រំដែនជាតិ" ចុះថ្ងៃ ២៧ ខែធ្នូ ឆ្នាំ១៩៨៥

បានកំណត់ព្រំដែនគោក ខ្មែរ-វៀតណាម ចាប់តាំងពីទិសខាងជើង ត្រង់ចំណុចប្រទល់ដែនរួម នៃប្រទេសទាំងបី គឺ ខ្មែរ-លាវ និង វៀតណាម (ចុះមកខាងក្រោម) ដោយគ្មានបានបញ្ជាក់ ពីនិយាមកា ភូមិសាស្ត្រ ឱ្យ បានពិតប្រាកដទេ រហូតមកដល់ឆ្នេរសមុទ្រ នៅលើចំណុចព្រំដែន លើឆ្នេរសមុទ្រខ្មែរ-វៀតណាម ដែលបានកំរិតដោយ កិច្ចព្រមព្រៀងស្តីពី "តំបន់ទឹកប្រវត្តិសាស្ត្រ" ចុះថ្ងៃ ៧ កក្កដា ១៩៨២ រួចមកហើយ។

សូមបញ្ជាក់ថា សន្ធិសញ្ញានិងកិច្ចព្រមព្រៀងទាំងនេះ ត្រូវបានបដិសេធចោល និង ផ្តន្ទាទោស ដោយ រាជរដ្ឋាភិបាលរបស់សម្តេច នរោត្តមសីហនុ នៅថ្ងៃទី ១២ ខែមិនា ឆ្នាំ១៩៨៦ (រដ្ឋាភិបាលកម្ពុជា ប្រជាធិបតេយ្យ ) ។
រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បានទទួលអស្សនៈរបស់ខ្លួននៅអង្គការ សហប្រជា-ជាតិ ក្រោយពី ពេលរដ្ឋាភិបាលសាធារណរដ្ឋ ខ្មែរទទួលបរាជ័យទៅ នៅក្នុងឆ្នាំ ១៩៧៥ ។
នៅក្នុងឆ្នាំ ១៩៧៩ ក្នុងពេលដែលប្រទេសវៀតណាមបានចូលមកលុកលុយនិង កាន់កាប់ប្រទេស កម្ពុជា អង្គការសហប្រជាជាតិមិនបានទទួលស្គាល់របបគ្រប់គ្រង ដែលបានតែងតាំងឡើងដោយ វៀតណាម ជាអ្នកឈ្លានពាននេះទេ ទោះបីមានការ តវ៉ាពីរបបនេះយ៉ាងណាក៏ដោយ ហើយតាមរយៈ សេចក្តីសំរេចចិត្តលេខ ៤៣/២២ នៅថ្ងៃទី ១៤ ខែវិច្ឆិការឆ្នាំ ១៩៧៩ អង្គការសហប្រជាជាតិបាន សម្រេចរក្សាអស្សនៈ កម្ពុជានេះឱ្យរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដដែល ។

បន្ទាប់មក ដើម្បីធ្វើការតទល់ជាមួយនឹងប្រទេសវៀតណាមឈ្លានពាន រដ្ឋាភិបាល នេះត្រូវបានរៀបចំ សារជាថ្មី ជារដ្ឋាភិបាលចម្រុះមួយវិញ ដែលមានចលនា ហ៊្វុនសិនប៉ិច ខាងខ្មែរក្រហម និង រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ដោយ មាន សម្តេច នរោត្តម សីហនុ ជាអ្នកដឹកនាំ ។ នៅក្នុងរដ្ឋាភិបាលថ្មីនេះ សម្តេច នរោត្តម សីហនុ ជាប្រធាន លោក ខៀវសំផន ជាអនុប្រធាន និងមានលោក សឺនសាន ជារដ្ឋមន្ត្រីទី១ ។
ប៉ុន្តែទោះបីគូភាគីទាំងបីនេះ មានបំណងតែមួយក្នុងការបណ្តេញកងទ័ពវៀតណាម ឱ្យចេញពីស្រុកខ្មែរ យ៉ាងណាក៏ដោយ ការចចារគ្នាបានប្រើពេលអស់យ៉ាងយូរទាំរាំ បានចេញជារដ្ឋាភិបាលនេះ ។ នៅទីបំផុត រដ្ឋាភិបាលនេះមានតែខាងផ្នែកនយោ-

បាយ និងយុទ្ធនាការសង្គ្រាមប៉ុណ្ណោះដែលរួមគ្នា ចំណែកខាងកងទ័ពវិញភាគីនិមួយៗ ធ្វើការត្រួតត្រាដោយផ្ទាល់នៅលើទ័ពនិមួយរបស់ខ្លួន ។

ឯលទ្ធផលនៃការធ្វើសង្គ្រាមរំដោះជាតិ ដែលបានប្រើរយៈពេល អស់ជាង មួយសតវត្ស នេះ គឺកិច្ចព្រម ព្រៀងសន្តិភាពនាទីក្រុងប៉ារីសស្តីពីកម្ពុជា ចុះថ្ងៃទី ២៣ ខែតុលា ឆ្នាំ ១៩៩១ ។

សន្ធិសញ្ញានេះត្រូវបានចុះហត្ថលេខាដោយភាគីខ្មែរទាំងបួន គឺ :

- ភាគីភ្នំពេញដែលតែងតាំងដោយវៀតណាម
- ភាគីហ្វ៊ុនសិនប៉ិច
- ភាគីកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម)
- និងភាគី រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ

ព្រមទាំងប្រទេសចំនួន ១៨ ទៀត ដែលបានចូលរួមនៅក្នុងសន្និសិទក្រុងប៉ារីសនេះដែរ មាន :

ប្រទេសអូស្ត្រាលី ប៊្រុយនេយ្យ កាណាដា ប្រទេសចិនប្រជាមានិតុ សហរដ្ឋអាមេរិក ប្រទេសបារាំង ឥណ្ឌា ឥណ្ឌូណេស៊ី ជប៉ុន លាវ ម៉ាឡេស៊ី ហ្វិលីពីន ប្រទេសអង់គ្លេស សិង្ហបូរី ថៃ សហភាពសូវៀត វៀតណាម និង យូហ្គោស្លាវី ក្រោមការគាំទ្រពីអង្គការសហប្រជាជាតិ ។

គួរកត់សំគាល់ថា នៅក្នុងពេលដែលប្រទេសវៀតណាមបានមកកាន់កាប់និងគ្រប់គ្រងប្រទេសកម្ពុជា នេះ គេបានបង្ខំឱ្យយកភាសាវៀតណាមជាភាសាយាននៅគ្រប់សាលារៀននិងគ្រប់មហាវិទ្យាល័យ ទាំងអស់។ ហេតុនេះគ្រូបង្រៀន និងសាស្ត្រាចារ្យទាំងអស់ មុននឹងបានចូលកាន់កាប់ការងាររបស់ខ្លួន ត្រូវតែទៅបំពេញការហ្វឹកហ្វឺនភាសានេះនៅវៀតណាមជាមុនសិន ។

# សន្ធិសញ្ញាក្រុងប៉ារីស ស្តីពីសន្តិភាពនៃប្រទេសកម្ពុជា នាថ្ងៃទី ២៣ ខែតុលា ឆ្នាំ ១៩៩១

VI-ដោយយោល ទៅលើហេតុការណ៍ ទាំងនោះហើយ ទើបសន្និសិទក្រុងប៉ារីស បាន សំរេចកិច្ចព្រម ព្រៀងមួយ ស្តីពីអធិបតេយ្យភាព ឯករាជ្យភាព បូរណភាព និង ភាពមិនអាចរំលោភបាន នៃទឹកដី អព្យាក្រឹតភាព និង ឯកភាពជាតិរបស់ប្រទេសកម្ពុជា ។ អព្យាក្រឹតភាពអចិន្ត្រៃយ៍របស់កម្ពុជា នឹង ត្រូវប្រកាសហើយ ចារិកទុកនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាដែលនឹងត្រូវអនុមតិបន្ទាប់ពីការបោះឆ្នោតដោយសេរីនិងត្រឹមត្រូវរួចមក។

យោងទៅតាមកិច្ចព្រមព្រៀងនេះនិងដើម្បីឱ្យបានដល់ទិសដៅខាងលើនេះ ប្រទេសកម្ពុជាបានសន្យា ជាឧឡារិកថា "នឹងបញ្ចប់នូវសន្ធិសញ្ញានិងកិច្ចព្រមព្រៀងទាំងឡាយណាដែលមិនសមស្របទៅនឹង អធិបតេយ្យភាព ឯករាជ្យភាព បូរណភាពនិងការមិនអាចរំលោភបាននៃទឹកដី អព្យាក្រឹតភាព និងឯកភាពជាតិរបស់ខ្លួន"។

ភាគីនានាក្នុងកិច្ចព្រមព្រៀងនេះ ហើយតាមរយៈសន្ធិសញ្ញានេះដែរ ក៏បានសន្យាជាឧឡារិកថា "ទទួលស្គាល់និងគោរពគ្រប់បែបយ៉ាងទាំងអស់ដល់អធិបតេយ្យភាព ឯករាជ្យភាព បូរណភាពនិង ភាពមិនអាចរំលោភបាននៃទឹកដី អព្យាក្រឹតភាពនិងឯកភាពជាតិរបស់កម្ពុជា"។

ដោយអនុវត្តន៍ទៅតាមសន្ធិសញ្ញានេះ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ១៩៩៣ បានចែងតាមប្រការពីរ មានជាអាទិថា ៖

ប្រការ ២: បូរណភាពទឹកដីកម្ពុជា មិនអាចរំលោភបាន នៅក្នុងព្រំដែនដែលបានកំរិតដោយផែនទី ខ្នាត ១/១០០.០០០ ដែលបោះពុម្ពក្នុងឆ្នាំ ១៩៣៣-១៩៥៣ ហើយដែលបានទទួលស្គាល់ជាអន្តរ-ជាតិ ពីឆ្នាំ ១៩៦៣-១៩៦៩ ។

ប្រការ ៥៥: សន្ធិសញ្ញានិងកិច្ចព្រមព្រៀងណា ដែលមិនសមស្របនឹងឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដី អព្យាក្រឹតភាព និងឯកភាពជាតិនៃប្រទេសកម្ពុជា នឹងត្រូវ លុបចោល"។

កិច្ចព្រមព្រៀងមួយចំនួនទៀតក៏បានចុះហត្ថលេខានៅពេលនោះដែរ ដូចជា : ការសម្របសម្រួល គ្នាក្នុងរយៈអន្តរកាល ការដកទ័ពបរទេសចេញពីប្រទេសកម្ពុជា និងការពិនិត្យនូវការដកទ័ពទាំងនេះ អំពីការបោះឆ្នោត អំពីបញ្ហាសិទ្ធិមនុស្ស កិច្ចធានាជាអន្តរជាតិ អំពីការជួសជុលនិងការកសាង សារជាថ្មីជាដើម ... ។ល។

## រដ្ឋាភិបាលក្បាលពីរ (១៩៩៣-១៩៩៧) និងរដ្ឋាភិបាលចំរុះ (ប្រជាជន-ហ៊្វុនសិនប៉ិច ១៩៩៨-២០០៣)

VII - រដ្ឋាភិបាលខ្មែរទី១ (មានសម្តេច នរោត្តមរណឫទ្ធិ ជានាយករដ្ឋមន្ត្រីទី ១ និង លោក ហ៊ុនសែន ជានាយករដ្ឋមន្ត្រីទី២) ដែលបានតែងតាំងឡើង ក្រោយពីមានការបោះឆ្នោតលើកទី១ នៅឆ្នាំ ១៩៩៣ រៀបចំឡើងដោយអង្គការ សហប្រជាជាតិនោះ មិនបានលុបចោល នូវសន្ធិសញ្ញា និងកិច្ច ព្រមព្រៀងខ្មែរ-វៀតណាមទាំងនោះទេ ។

ឯចំណែកការចរចារគ្នារវាងសម្តេច នរោត្តមរណឫទ្ធិ និងរដ្ឋមន្ត្រីទី១វៀតណាម វ៉ូវ៉ាន់កៀត នៅថ្ងៃទី ១៦ ខែមករា ឆ្នាំ១៩៩៥ ទៀយសោត ក៏ឥតបានលើកមកជា មូលដ្ឋាននូវសន្ធិសញ្ញាក្រុងប៉ារីសឆ្នាំ ១៩៩១ នោះក៏ទេដែរ ។

ផ្ទុយទៅវិញគណកម្មការចម្រុះខ្មែរ-វៀតណាម ដែលមានលោក វ៉ាគិមហុង ជាតំណាងគណៈប្រតិភូ ខ្មែរ និងលោក ត្រាន់កាងទ្រឹក ភាគីខាងវៀតណាម នៅពេលចរចារគ្នាពីថ្ងៃទី ២២ ដល់ថ្ងៃទី ២៧ មិនា ឆ្នាំ១៩៩៩ នៅក្រុង ហូជីមិញ បែរជាបានសម្រេចដូចតទៅវិញថា ៖

"យល់ព្រមលើគោលការណ៍សំខាន់ក្នុងកិច្ចចរចារ និងសេចក្តីសំរេចក្នុងរឿងព្រំដែន រវាងប្រទេស ទាំងពីរ ដែលត្រូវផ្អែកទៅលើកិច្ចព្រមព្រៀងនិងសន្ធិសញ្ញាជាធរមាន ក្នុងឆ្នាំ ១៩៨២ ១៩៨៣ និង ១៩៨៥" និង "សន្យាថា និងគោរពសន្ធិសញ្ញាស្តីពី "គោលការណ៍ដើម្បីដំណោះស្រាយព្រំដែន" ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣, កិច្ចព្រមព្រៀងស្តីពី "លក្ខន្តិកៈព្រំដែន" ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ សន្ធិសញ្ញាស្តីពី "ការកំណត់ព្រំដែនជាតិ" ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៨៥ ថែមទាំង សន្យាថានឹងគោរពការដាំបង្គោលខណ្ឌសីមាដែលធ្វើរួចមកហើយពីឆ្នាំ ១៩៨៦ ដល់ ១៩៨៨" ។

ឯចំពោះព្រំដែនសមុទ្រវិញនោះ ប្រតិភូខ្មែរក្នុងគណៈកម្មការចំរុះខ្មែរវៀតណាម បាន បញ្ជាក់អំពីគោល ជំហរក្នុងការយក "ខ្សែបន្ទាត់ប្រេវិយេ" ឆ្នាំ ១៩៣៩ ជា ព្រំដែនសមុទ្រ រវាងប្រទេសទាំងពីរ។ ប្រតិភូខាងវៀតណាមមិនព្រមយក "ខ្សែបន្ទាត់ប្រេវិយេ" នេះ ធ្វើជាព្រំប្រទល់សមុទ្ររវាងប្រទេស ទាំងពីរទេ" ។

នៅទីបញ្ចប់គណៈរដ្ឋមន្ត្រីពេញអង្គ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០០ បានយល់ព្រម

លើការងារទាំងអស់ ធ្វើឡើងដោយគណៈកម្មការចម្រុះខ្មែរ-វៀតណាមនេះ ។

ទាំងនេះបានសេចក្ដីថារដ្ឋាភិបាលខ្មែរទាំងពីរ រហូតមកទល់ថ្ងៃនេះមិនបានគោរពកិច្ចព្រមព្រៀងក្រុង ប៉ារីស និងរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាទេ ។

## រដ្ឋាភិបាលកញ្ចប់ ឆ្នាំ ២០០៤

ចំពោះគណបក្ស ហ៊្វុនសិនប៉ិច វិញ យើងអាចសង្កេតឃើញថា ក្រោយពីបាននៅស្ងៀមស្ងាត់ អស់រយៈ ពេលមួយយ៉ាងយូរ ដែលគ្មានអ្វីនឹងគួរឱ្យសង្ស័យនោះ (ពេលនោះគណបក្ស នេះបាន ចូលរួមនៅក្នុងរដ្ឋាភិបាលចម្រុះជាមួយគណបក្សប្រជាជន) រហូតមកដល់ ពេលមានរដ្ឋប្រហារ ក្នុងឆ្នាំ ១៩៩៧ ទើបគណបក្សហ៊្វុនសិនប៉ិចនេះបានខិតខំទាមទារយ៉ាងស្វិតស្វាញ ដើម្បីឱ្យលុបចោលនូវសន្ធិសញ្ញា របស់ប្រទេសវៀតណាមមកលើប្រទេសកម្ពុជាទាំងនេះ ។
នៅពេលធ្វើយុទ្ធនាការបោះឆ្នោតនៅពេលចុងក្រោយក្នុងឆ្នាំ ២០០៣ ក៏យ៉ាងដូចនោះដែរ ។
ប៉ុន្តែ ជាការមួយដែលធ្វើឱ្យមតិមហាជនឆ្ងល់ជាខ្លាំង នៅថ្ងៃទី ០២ ខែមិថុនា ឆ្នាំ ២០០៤ បន្ទាប់ មក ក្រោយពីបាន "ពិភាក្សា/សម្បទានគ្នាទៅវិញទៅមក" ជាមួយលោក ហ៊ុនសែន ជាលើកទី ២ មក ស្រាប់តែសម្ដេចក្រុមព្រះ ប្រែជាទទួលជាមួយលោក ហ៊ុនសែន នេះ ថាមិនលុប សន្ធិសញ្ញាដែលមានជាមួយប្រទេសវៀតណាម ទាំងនោះទៅវិញ ដោយបានផ្ដល់ សេចក្ដីពន្យល់ យ៉ាងសោកស្ដាយមួយដែលគេតែងបានឮរួចមកហើយនៅទីដទៃទៀត : "យើងមិនអាចលុប សន្ធិសញ្ញាទាំងនោះ ចោលទេ ដោយហេតុថា បើគ្មានសន្ធិសញ្ញាទាំងនោះ ទេ យើងគ្មានអ្វីជា មូលដ្ឋានដើម្បីនឹងយកទៅជជែកជាមួយនឹងអ្នកជិតខាង យើងនោះ ទេ" ។
ប៉ុន្តែសម្ដេចក្រុមព្រះ បានបើក "ច្រកចេញ" មួយ គឺការបង្កើតនៅនាពេលខាងមុខនេះ នូវ "ក្រុមប្រឹក្សាជាន់ខ្ពស់ទទួលបន្ទុក កិច្ចការព្រំដែន ដែលមានតំណាងគណបក្សទាំងអស់ជាសមាជិក និងដឹកនាំដោយតំណាងរបស់ព្រះមហាក្សត្រជាប្រធាននេះ ដើម្បីស្វែង រកដំណោះស្រាយរួម មួយដែលត្រូវយក" ។
ចំពោះយើងវិញ យើងបានសង្កេតឃើញថា ចាប់តាំងពីឆ្នាំ ១៩៩៩ មកម្ល៉េះ លោក ហ៊ុនសែន លោកមានការស្រឡាញ់ ចូលចិត្តណាស់ គឺយកវរជនដែលមិនមែនមក

ពីគណបក្សប្រជាជន ទៅឱ្យ ទទួលខុសត្រូវនៅក្នុងកិច្ចការព្រំដែន ឬមួយនៅក្នុងបញ្ហាជនអន្តោប្រវេសន៍យួននៅប្រទេសកម្ពុជា ។

នេះជាមធ្យោបាយមួយដើម្បីប្រគល់ទៅឱ្យអ្នកដែលជាអតីតអ្នកប្រឆាំងនោះ ឱ្យទទួលការ ខុសត្រូវ ក្នុងរឿងនេះ តែគោលដៅពិត គឺដើម្បីនឹងដាក់អ្នកទាំងអស់នេះឱ្យនៅក្រោម និងធ្វើ តាមគោល បំណង របស់លោកនាយករដ្ឋមន្ត្រីហ៊ុនសែនដែលមានអនុភាព យ៉ាងសែនអស្ចារ្យតែប៉ុណ្ណោះ ។

សម្តេច នរោត្តម រណឫទ្ធិ ដែលជាអ្នកចំណានម្នាក់នៅក្នុងវិស័យច្បាប់អន្តរជាតិលោកប្រាកដ ជាមិនមាន ការសង្ស័យអ្វីនោះ ឡើយថា ការដែលធ្វើសម្បទានគ្នាទៅវិញទៅមក ការសម្របគ្នា ដោយស្ងាត់ស្ងៀម នៅលើបញ្ហាមួយដែលជាអាយុជីវិត គឺបញ្ហាព្រំ ប្រទល់របស់ប្រទេសយើងនេះ មាន ហើយនឹងមានតទៅទៀតនូវផលវិបាកដូចតទៅនេះ :

១-នាំឱ្យមានការការលុបចោលនូវការទទួលស្គាល់របស់រដ្ឋាភិបាលក្រុងហាណូយ និងលោក ផាំវ៉ាន់ដុង ពីឆ្នាំ ១៩៥៤ ដល់ ឆ្នាំ ១៩៧០ ដែលបានថ្លែង "ក្នុងនាមប្រទេសវៀតណាមទាំងមូល" ថាទទួលស្គាល់បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុង ព្រំដែនដែលគេបានទទួលស្គាល់ជាអន្តរជាតិនាសន្និសិទទីក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤

២-នាំឱ្យមានការទទួលស្គាល់សន្ធិសញ្ញានិងកិច្ចព្រមព្រៀងទាំងអស់ដែលមានរវាងសាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋប្រជាមានិតុកម្ពុជាដែលបានចុះហត្ថលេខាក្នុងឆ្នាំ ១៩៧៩, ១៩៨២, ១៩៨៣ និង ១៩៨៥ និងសេចក្តីសំរេច នានា ដែលគណកម្មការ ចម្រុះខ្មែរ-វៀតណាមបានធ្វើចាប់តាំងពីឆ្នាំ ១៩៩៩ មក រហូតមកដល់ពេល ឥឡូវនេះ ថាមានលក្ខណៈត្រឹមត្រូវតាមច្បាប់

៣-នាំឱ្យមានការទទួលស្គាល់ដោយជាក់ច្បាស់ដោយប្រទេសកម្ពុជានូវ អនុភាពនៃសន្ធិសញ្ញាថ្មី ដែល បាន ចុះហត្ថលេខា រវាងប្រទេសវៀតណាម និងប្រទេសថៃឡង់ ដែលធ្វើនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីអំពីព្រំប្រទល់ចុងក្រោយ នៃដែនសមុទ្រ របស់ប្រទេស ទាំងពីរនេះមកលើអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា

៤-បានរំលោភយ៉ាងខ្លាំងទៅលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ ១៩៩១

ផង និងទៅ លើរដ្ឋធម្មនុញ្ញនៃព្រះរាជា-ណាចក្រកម្ពុជា នៅក្នុងមាត្រា ៥៥ ផង ដែលបង្ខំឱ្យបញ្ចប់ "សន្ធិសញ្ញានិងកិច្ចព្រមព្រៀងទាំងឡាយណាដែលមិនសមស្របទៅ និងឯករាជភាព អធិបតេយ្យភាព បូរណភាពទឹកដី អព្យាក្រិតភាព និងឯកភាពជាតិ នៃព្រះរាជាណាចក្រ កម្ពុជា"

៥-លែងទទួលស្គាល់សុពលភាពនៃផែនទីភូមិសាស្ត្ររបស់ប្រទេសកម្ពុជាទាំងអស់ ដែលបាន រៀបចំ ឡើងពីឆ្នាំ ១៩៦៣ ដល់ ១៩៦៩ ដែលមានការទទួលស្គាល់ជាឧឡារិក និង ជាអន្តរជាតិរួចហើយដែលក្នុងនោះមានរដ្ឋាភិបាលរបស់ក្រុង ហាណូយផង

៦-អនុញ្ញាត ក្នុងពេលជាមួយគ្នានេះដែរ ដល់អាណានិគម ជនយួន ចំនួនរាប់លាន នាក់ឱ្យបន្ត ការចូលមករស់នៅ និងតាំង លំនៅដ្ឋានតាមអំពើចិត្តនៅគ្រប់តំបន់នានាដែលសំខាន់ៗ ខាងផ្លូវសេដ្ឋកិច្ច សង្គមកិច្ច ក៏ដូចជាខាងផ្លូវនយោបាយ ក្រោមកិច្ចការពារ មិនដាច់ពី អ្នកកាន់អំណាចនៃគណបក្សប្រជាជន ។ ទង្វើនេះ នឹងធ្វើឱ្យការរស់នៅជារៀងរាល់ថ្ងៃ និងឯកភាពជាតិរបស់ខ្មែរទទួលគ្រោះថ្នាក់ជាខ្លាំង ។

រាជរដ្ឋាភិបាល ដែលមាន កាតព្វកិច្ចក្នុងការការពារឯករាជភាព អធិបតេយ្យភាព និងបូរណភាព ទឹកដី ដោយយោងទៅលើមាត្រា លេខ ៥២ នៃរដ្ឋធម្មនុញ្ញ មិនត្រូវនៅស្ងៀមព្រងើយកន្តើយ ឥតសកម្មភាពនៅចំពោះមុខបញ្ហាដែលជាអាយុជីវិតនេះទេ ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាល ត្រូវតែចាត់វិធានការណ៍ ដើម្បីបញ្ចប់សន្ធិសញ្ញាដែលខុសច្បាប់ទាំងអស់នេះចេញ ដោយហេតុថា ភាពទន់ខ្សោយណាមួយនៅក្នុងការការពារបូរណភាពទឹកដីនេះ មិនអាចមានផល អ្វីមួយក្រៅអំពីការបាត់បង់ ការខូចខាតនិងការ ផុតរលត់ទៅនៃមាតុភូមិ និងប្រជាជាតិរបស់យើងនោះឡើយ តទៅអនាគត ។

# ចុតហ្មាយព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

អត្ថបទព្រះករុណា  នរោត្តម  សីហនុ
ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
(បកប្រែក្រៅផ្លូវការ)

## សេចក្តីថ្លែងការណ៍ របស់ នរោត្តម សីហនុ
## ប៉េកាំង ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៤

មានខ្មែរខ្លះដែលរស់នៅឯបរទេស  មានជំនឿដោយច្រឡំថា  ខ្ញុំបានប្រាប់ទៅគណប្រតិភូរបស់គណបក្សកុម្មុយនិស្តនៃសាធារណរដ្ឋសង្គមនិយមវៀតណាម  ដែលបានមកគាល់ខ្ញុំនៅក្នុងព្រះបរមរាជវាំងនៅភ្នំពេញថា  ខ្ញុំសុខ  ចិត្តទទួលទៅមើលព្រំដែនខ្មែរ-វៀតណាម  ដើម្បីនឹងពិនិត្យបញ្ជាក់  ជាមួយនឹងភាគីវៀតណាម  លើការកែរតម្រូវគំនូសព្រំដែនរវាងប្រទេសទាំង  ពីរក្នុងមូលដ្ឋាន  សន្ធិសញ្ញាប្រទេសកម្ពុជាលោក  ហេងសំរិន  និងសាធារណរដ្ឋសង្គមនិយមវៀតណាម  ដែលមានចុះហត្ថលេខានៅក្នុងឆ្នាំ  ១៩៨០  នោះ។  គឺជាការមួយដែលខុសស្រឡះ  ចំពោះខ្ញុំ  ដែលនិយាយពីការទទួលពីខ្ញុំនូវសន្ធិសញ្ញាដែលមាននៅក្នុងឆ្នាំ  ១៩៨០  ។

ខ្ញុំបានបញ្ជាក់  យ៉ាងច្បាស់លាស់  ដល់គណប្រតិភូ  នៃគណបក្សកុម្មុយនិស្តនៃសាធារណរដ្ឋសង្គមនិយមវៀតណាមថា  គឺគំនូសព្រំដែន  យើងដែលមានបង្ហាញ  យ៉ាងច្បាស់លាស់នៅលើផែនទី  ដែលធ្វើដោយប្រទេសបារាំង  និងដោយសហរដ្ឋអាមេរិក  ពីឆ្នាំ  ១៩៦៣  ដល់  ១៩៦៩  ដែលខ្ញុំនិយាយ  ជា

គំនូស ដែលបានទទួលស្គាល់ដោយជាក់លាក់ ដោយសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម របស់ ឯ.ឧ. ផាំវ៉ាន់ដុង រដ្ឋាភិបាលបណ្ដោះអាសន្ន និងរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង របស់លោក ហ្វិញ តាន់ផាត់ និងលោកប្រធាន ង្វៀងហុលីថ ៕

ហត្ថលេខា :
នរោត្តមសីហនុ
ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

បកប្រែក្រៅផ្លូវការដោយគណកម្មាធិការព្រំដែនកម្ពុជា
នៅប្រទេសបារាំង និងនៅលើពិភពលោក
ប៉ារីសថ្ងៃទី ១៣ កញ្ញា ឆ្នាំ ២០០៤

អត្ថបទរបស់ព្រះករុណា នរោត្តម សីហនុ
(បកប្រែក្រៅផ្លូវការ)

នរោត្តម សីហនុ : អត្ថបទទី២របស់ខ្ញុំ សម្រាប់ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣

១)ស្តីអំពីសារមួយក្នុងពេលថ្មីៗនេះ ដែលសម្តេចក្រុមព្រះ ន.រណឫទ្ធិ បានផ្ញើរមកខ្ញុំ ទូលសុំឱ្យខ្ញុំថាយ៉ាងដូចនេះ-យ៉ាងដូចនោះ ទៅសម្តេច ហ៊ុនសែន សារពតិមានខ្លះ បានធ្វើការបកស្រាយដោយមិនត្រឹមត្រូវអំពី "ការបដិសេធ" ពីខ្ញុំ លើពាក្យសុំដោយប្រធានគណបក្សហ្វ៊ុនសិនប៉ិច ស្តីអំពីព្រំប្រទល់ដែនរបស់ជាតិយើង ។

ចំពោះបញ្ហានេះ ខ្ញុំមានកាតព្វកិច្ចនឹងធ្វើការកែតម្រូវដូចតទៅនេះ ៖

២) ខ្ញុំ ក៏ដូចជាខ្មែរអ្នកស្នេហាជាតិដទៃទៀតដែរ ខ្ញុំទទួល ហើយខ្ញុំនឹងទទួលយកសម្រាប់ប្រទេសកម្ពុជាតែគំនូសជាផ្លូវការណ៍ នឹងដែលបានទទួលស្គាល់ជាអន្តរជាតិ (រួមទាំង ស.រ.អា. ក្នុងឆ្នាំ ១៩៦៩ ផង) នៃព្រំដែនដីគោក ក៏ដូចជាព្រំដែនសមុទ្ររបស់ប្រទេសកម្ពុជាដែរ ដែលមាននៅក្នុងឆ្នាំ ១៩៦៣ (ក្រោយពីការកាត់ក្តីដោយយុត្តិធម៌របស់តុលាការអន្តរជាតិនៅឡាអេ ស្តីអំពីភ្នំនិងប្រាសាទព្រះវិហាររបស់ខ្មែរក្នុងឆ្នាំ ១៩៦២) និងក្នុងឆ្នាំ ១៩៦៩ (មុនពេលដែលក្រុម លន់នល់-សិរិមតៈ បានធ្វើរដ្ឋប្រហារនៅក្នុងថ្ងៃទី ១៨ ខែមិនា ឆ្នាំ ១៩៧០) ។

៣) ខ្ញុំមិនទទួលស្គាល់ ហើយនឹងមិនទទួលស្គាល់ទេ នូវសន្ធិសញ្ញាដែលបានចុះហត្ថលេខាដោយរបបខ្មែរដែលរណបសាធារណរដ្ឋសង្គមនិយមវៀតណាម (១៩៧៩-១៩៩០) និងសន្ធិសញ្ញារវាងរដ្ឋនៅក្នុងឥណ្ឌូចិនដទៃៗទៀត

ឬ មួយរវាងថៃនិងយៀកណាម ឬមួយរវាងថៃនិងវៀតណាម ដែលមានការប៉ះពាល់ដល់បូរណភាពទឹកដី ដល់គំនូសព្រំដែនដីគោកនិងព្រំដែនសមុទ្ររបស់ប្រទេសកម្ពុជា ដែលមានក្នុងឆ្នាំ ១៩៦៣ និង ១៩៦៩ ។

៤) ក្នុងឋានៈខ្ញុំជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា (ព្រះរាជាណាចក្រទី ២) ខ្ញុំនិងមិនចុះហត្ថលេខានៅលើសន្ធិសញ្ញាព្រំដែន ដែនដីគោក និងដែនសមុទ្ររបស់ "ព្រះរាជាណាចក្រថ្មី" របស់ខ្មែរជាមួយ នឹងប្រទេសជិតខាង (សាធារណរដ្ឋសង្គមនិយមវៀតណាម ប្រទេសថៃឡង់ ប្រទេសឡាវ) ដោយសារសន្ធិសញ្ញាទាំងនេះ នឹងមិនធានាការរក្សាគំនូសព្រំដែនដីគោកនិងដែនសមុទ្ររបស់ព្រះរាជាណាចក្រកម្ពុជា ដែលមានក្នុងឆ្នាំ ១៩៦៣ និង ១៩៦៩ នោះទេ ។

៥) ជាទីបញ្ចប់ គណបក្សហ៊្វុនសិនប៉ិច (ក៏ដូចគណបក្សប្រជាជន និងគណបក្សសមរង្ស៊ីដែរ) ដែលត្រូវបានជ្រើសរើសដោយប្រជាជាតិ ជាអធិបតី ដើម្បីគ្រប់គ្រងអំណាចរដ្ឋទាំងអស់នៅក្នុងនាមរបស់លោក ដូចនេះការរ៉ាប់រ៉ងនៅក្នុងកិច្ចការប្រទេសនិងកិច្ចការជាតិទាំងអស់ ត្រូវតែធ្វើការទាក់ទងដោយផ្ទាល់ជាមួយរាជរដ្ឋាភិបាលកម្ពុជា និងអ្នកដឹកនាំនៃរដ្ឋាភិបាលនេះ ដោយមិនចាំបាច់រត់រកជំនួយពីព្រះមហាក្សត្រនោះឡើយ ។

ព្រះរាជហត្ថលេខា : នរោត្តម សីហនុ

បកប្រែក្រៅផ្លូវការដោយគណកម្មាធិការព្រំដែនកម្ពុជា
នៅប្រទេសបារាំង និងលោកពិភពលោក
ប៉ារិសថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០០៣

អត្ថបទរបស់ព្រះករុណា នរោត្តម សីហនុ
(បកប្រែក្រៅផ្លូវការ)

នរោត្តម សីហនុ: អត្ថបទ ទី ២ របស់ខ្ញុំ សំរាប់ថ្ងៃទី ២១ ខែមិនា ឆ្នាំ ២០០៤

"ប្លាក់អៅត៍" ពេញទី ។ កិច្ចព្រមព្រៀងដ៏អស្ចារ្យមួយ នឹងបានសម្រេច ក្នុងពេលឆាប់នេះ រវាងស្តេចក្រុមព្រះ ន.រណឫទ្ធិ (ហ្វ៊ុនសិនប៉ិច) និង គណបក្សប្រជាជន (សម្តេច ជាសិម និងសម្តេច ហ៊ុនសែន) : ការ ចែកអំណាច និងប្រយោជន៍ដែលគួរឱ្យរំភើបមួយរវាងគណបក្សទាំង ពីរនេះ នៅគ្រប់ស្ថាប័នទាំងអស់របស់ប្រទេសខ្មែរយើង (រាជរដ្ឋាភិបាល ព្រឹទ្ធសភា រដ្ឋសភាជាតិ រដ្ឋបាលជាតិនៅគ្រប់ជាន់ថ្នាក់) ។ ស្តេចក្រុមព្រះ ន.រណឫទ្ធិ នឹងទៅជា"ព្រះប្រធាននៃរដ្ឋសភាជាតិ"ម្តងទៀត ។ ប៉ុន្តែខ្ញុំសូមនិយាយម្តងទៀត : "ប្លាក់អៅត៍" ពេញទី ..."នៅពេលនេះ" ។ អ្នកពត៌មាននានាមិនត្រូវឱ្យ ដឹងពីភាពល្អិតល្អន់នៃ "ការសម្រុះសម្រួល" នេះទេ ។ "អ្នកដែលចង់ដឹង" ដទៃទៀត ក៏យ៉ាងដូចនោះដែរ ។ សម្រាប់អ្នកទាំងនេះ ទាំងស្រីទាំងប្រុស គេនឹងធ្វើសេចក្តីថ្លែងការណ៍ពត៌មានយ៉ាងវែងមួយ "នៅក្នុងពេលតាមការ គួរ" ។

*

*    *

ចំពោះគណបក្សសមរង្ស៊ីដែលឆ្មើម និង "ស្អាតស្អំ" របស់ ឯ.ឧ. សមរង្ស៊ី វិញ : មានពីរយ៉ាង ឬមួយ នឹងមានអ្នកដែលនៅក្នុងគណបក្សសមរង្ស៊ី នៅ ក្នុងចំណោមអ្នកនៅក្នុងហ្វ៊ុនសិនប៉ិច ដែលនឹងទទួល "កិច្ចការ" មុខតំណែង និងកន្លែងសំខាន់ៗ ពីព្រះអាទិទេពគណបក្សប្រជាជន របស់លោក ហ៊ុនសែន នៅពេលនោះ "អ្នកស្អាតស្អំនិងមិនអាចសម្របសម្រួលបាន" (ដោយ

មិនព្រមធ្វើការសម្របសម្រួលដោយប្រការណាមួយនោះ) គណបក្សសមរង្ស៊ី នឹង បាត់បង់យ៉ាងហោចណាស់ក៏ ៨០% នៃប្រជាប្រិយភាពរបស់ខ្លួន ជំនឿដែលគេមានមកលើខ្លួន និងឆពណ្ណរង្សី គឺកត្តិនាមរបស់ខ្លួន នៅចំពោះមុខយុវជននិងខ្មែរដទៃទៀត ទាំងស្រីទាំងប្រុសដែលប្រឆាំងនឹងលោក ហ៊ុនសែន ឬមួយនឹងមិនមានអ្នកនៅក្នុងគណបក្សសមរង្ស៊ី ក្នុងចំណោមអ្នកដែលនៅក្នុងគណបក្សហ្វ៊ុនសិនប៉ិច ដែលបានទទួលម្ហូបទិព្វដែលបានមកពីព្រះអាទិទេព គណបក្សប្រជាជន ។ ពេលនោះ គឺជាទីអវសានជាផ្លូវការ ឬដែលអាចនឹងកើតមានក្នុងថ្ងៃខាងមុខ នៃ "សម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យ" ដ៏ល្បីល្បាញ ព្រមទាំងការវាយប្រហារ "តាមក្បួនខ្នាត" និងជានិរន្តរទៅលើស្ដេចក្រុមព្រះ និងគណបក្សហ្វ៊ុនសិនប៉ិចរបស់ព្រះអង្គ ដោយគណបក្សសមរង្ស៊ីនិងអ្នកដឹកនាំដ៏ល្បីល្បាញនៃគណបក្សនេះ ។ "អ្វីដែលអភ័ព្វ ប្រែជាល្អទៅវិញ" : របបសភាតាមរបៀបប្រជាធិបតេយ្យសេរីរបស់យើង នឹងមានអ្នកប្រឆាំងរដ្ឋាភិបាលមួយដែលខ្លាំងក្លា មាំមួន និងស្វាហាប់ជានិច្ច ។

*

*    *

សំនួរមួយយ៉ាងសំខាន់ :តើរាជរដ្ឋាភិបាលថ្មី របស់លោក ហ៊ុនសែន នឹងហ៊ានបញ្ចូលទៅក្នុង "ផ្លាត់ហ្វម" គឺ "កម្មវិធីនយោបាយ" របស់ខ្លួន នូវបញ្ហាបូរណភាពទឹកដីរបស់ប្រទេសកម្ពុជា និងបញ្ហាជនអន្តោប្រវេសន៍ ឱ្យបានស្របទៅតាមពាក្យសន្យា របស់ស្ដេចក្រុមព្រះ ន.រណឫទ្ធិ ក្នុងពេលបោះឆ្នោត ឬទេ ?

ព្រះរាជហត្ថលេខា:
នរោត្ដម សីហនុ

បកប្រែក្រៅផ្លូវការដោយគណកម្មាធិការព្រំដែនកម្ពុជា
នៅប្រទេសបារាំង និងនៅលើពិភពលោក
ប៉ារីសថ្ងៃទី ១៣ កញ្ញា ឆ្នាំ ២០០៤

អត្ថបទរបស់ព្រះករុណា នរោត្តម សីហនុ
(បកប្រែក្រៅផ្លូវការ)

នរោត្តម សីហនុ : អត្ថបទទី ៤ របស់ខ្ញុំ សំរាប់ថ្ងៃទី ១២ ខែមិនា ឆ្នាំ ២០០៤

ការមិនកំប្លែង ដោយ នរោត្តម សីហនុ

តេវេកា នៅល្ងាចថ្ងៃទី ១១ ខែមិនា ឆ្នាំ ២០០៤ បានផ្សាយថា នៅពេលយ៉ាងខ្លីខាងមុខនេះ នឹងមានការជួបគ្នាជាកំពូលរវាងសម្តេច ន.រណឫទ្ធិ និងសម្តេច ហ៊ុនសែន ដើម្បីនឹងដោះស្រាយ នៅទីបំផុត បញ្ហាដែលហៅថា "ឱដឡក់" ហៅម្យ៉ាងទៀតថា "វិបត្តិនយោបាយ" ។
ដោយសម្តេច រណឫទ្ធិ បានធ្វើដំណើរទៅមុខជ្រុលហួសហើយ ក្នុង មាគ៌ាការពារត្រីភាគី ដើម្បីនឹងបង្កើត រាជរដ្ឋាភិបាលថ្មី នៃព្រះរាជាណាចក្រកម្ពុជា បើតាមក្បួន គឺនៅសល់សំរាប់មនុស្សខ្លាំងរបស់យើង តែការទទួលយករូបមន្ត ត្រីភាគីតែប៉ុណ្ណោះ ។
ប៉ុន្តែ នៅមាន នឹងនៅមានជានិច្ច "របស់" មួយ ដែលគណបក្សប្រជាជនមិនអាចនឹងទទួលយកបានសោះឡើយគឺ : ការប៉ះទង្គិចជាមួយនឹងសាធារណរដ្ឋសង្គមនិយមវៀតណាម នៅក្នុងបញ្ហាព្រំប្រទល់ដែន និងបញ្ហាជនអន្តោប្រវេសន៍ ។
អ្នកនយោបាយធំៗខ្លះនៅភ្នំពេញ ចូលចិត្តធ្វើឫកជាអ្នកក្លាហាន ដោយបាន

ប្រកាសថា "បញ្ហា" នឹងត្រូវដោះស្រាយ "មុនពេលត្រឡប់មកវិញរបស់ព្រះករុណា" ។ អ្នកទាំងនេះបានប្រកាសទៀតថា "បញ្ហា" (ដែលឱ្យអាប់យស) នេះ នឹងត្រូវបញ្ចប់ "មុននឹងព្រះករុណាយាងទៅប៉េកាំង" ។

ខ្ញុំសូមអរគុណដល់អ្នកនយោបាយដែលល្បីល្បាញទាំងនេះ ដែលបានធ្វើទុក្ករកម្ម ខាងផ្លូវចិត្តមកលើរូបខ្ញុំ ដោយបានថ្វាយដល់ខ្ញុំដោយមិនគប្បី និងដោយ ចង្រៃ តៗគ្នានូវ "ស្រមោលដែលមិនពិត" នេះ ។ ការធ្វើនេះប្រហែល ជាធ្វើឱ្យប្រជារាស្ត្រយើងមួយក្រុមមានការសប្បាយរីករាយ ។ សាធុ សាធុចុះ !

ហត្ថលេខា :
នរោត្តម សីហនុ

បកប្រែក្រៅផ្លូវការដោយគណកម្មាធិការព្រំដែនកម្ពុជា
នៅប្រទេសបារាំង និងនៅលើពិភពលោក
ប៉ារីសថ្ងៃទី ១៣ កញ្ញា ឆ្នាំ ២០០៤

ព្រះករុណាព្រះបាទសម្ដេច
ព្រះនរោត្តម សីហមុនី
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

ជូន ឯកឧត្តម Sean Pengsè
ប្រធានគណៈកម្មាធិការព្រំដែនកម្ពុជានៃប្រទេសបារាំង និងនៅក្នុងសកលលោក

ឯកឧត្តមជាទីរាប់អាន និងស្រឡាញ់ដ៏ជ្រាលជ្រៅ

ខ្ញុំបានទទួលរួចហើយលិខិត ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៩ របស់ឯកឧត្តមស្ដីពីបញ្ហាព្រំដែនកម្ពុជា ជាមួយប្រទេសជិតខាង ។

ខ្ញុំសូមសំដែងនូវអំណរគុណដ៏ជ្រាលជ្រៅ ហើយសូមកោតសរសើរ និងសរសើរដ៏កក់ក្ដៅបំផុតចំពោះស្នេហាជាតិដ៏បរិសុទ្ធរបស់ឯកឧត្តម និងសមាជិក សមាជិកាទាំងអស់នៃគណៈកម្មាធិការព្រំដែនកម្ពុជានៃប្រទេសបារាំង និងនៅក្នុងសកលលោក ។

មានថ្ងៃមួយ នៅមហាប្រាសាទខេមរិន្ទ ឯកឧត្តម វ៉ា គឹមហុង លោកបានប្រាប់ខ្ញុំថា កម្ពុជាយើងចំណេញ ព្រោះថ្ងៃនេះកម្ពុជាបច្ចុប្បន្នមានទំហំធំជាងថ្ងៃនេះកម្ពុជានៅចន្លោះឆ្នាំ១៩៥៣ ដល់ឆ្នាំ១៩៦៩ ។ នេះគឺដោយសារសុច្ឆន្ទៈនៃសាធារណរដ្ឋសង្គមនិយម វៀតណាម លោកបានធ្វើសម្បទានជូនកម្ពុជា ។

ចំណែកខ្ញុំវិញ ខ្ញុំគ្មានអំណាចប្រតិបត្តិឡើយ ។ ខ្ញុំនៅតែប្រកាន់ជាប់ជានិច្ចនូវអ្វីដែលខ្ញុំបានថ្លែង និងសរសេរ ហើយតទៅមុខទៀតខ្ញុំមិនកែប្រែជំហររបស់ខ្ញុំពីបញ្ហាបូរណភាពទឹកដីនៃកម្ពុជាយើងទេ ។

សូមឯកឧត្តម ទទួលនូវសេចក្ដីរាប់អាន និងស្រឡាញ់ដ៏ជ្រាលជ្រៅ អំពីខ្ញុំ ។

*Haute considération.*
*Avec ma plus profonde affection.*

នរោត្តម សីហមុនី

ប៉េកាំង ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៩

# សមាសភាព គណៈកម្មាធិការព្រំដែនកម្ពុជា

តាមសេចក្តីសំរេច នៃមហាសន្និបាត របស់គណៈកម្មាធិការព្រំដែនកម្ពុជានា ថ្ងៃទី ១៥ ធ្នូ ២០០១ សមាសភាព របស់ ការិយាល័យ នៃ គណៈកម្មាធិការ ព្រំដែនកម្ពុជា មាន ដូចត ទៅ ៖

១ - ប្រធាន : លោក ស៊ាន ប៉េងសែ

២ - អនុប្រធាន : លោក ឌីការ៉េត

៣ - អគ្គលេខាធិការ : លោក ស៊ាន ម៉ាសាវ៉ាង

៤ - អគ្គលេខាធិការរង : លោក តាន់ វ៉ាន់កែវ

៥ - អគ្គហិរញ្ញិក : លោក ហម ប៊ុនឆាយ

៦ - អគ្គហិរញ្ញិករង : លោក ឈុយ សុខ

# សមាជិកគណកម្មការនាយក ផ្សេងទៀតមាន

| | |
|---|---|
| ១-លោក ចៅ សេង អ៊ួ | ២-លោក ងួវ បេង អ៊ាម |
| ៣-លោក ហាក់ ព្រូ | ៤-លោក នាង ជិន ហន |
| ៥-លោក អ៊ឹង ប៊ុន ភាវ | ៦-លោក ស្រី ចក់ សារឿន |
| ៧-លោក សេង អឿន | ៨-លោក អ៊ួ ចល់ |
| ៩-លោក ខៀវ ឡេង | ១០- លោក ឌួង សំអុល |
| ១១-លោក បាន ម៉ាសារិន | ១២-លោក ស៊ុយ សេង ហេង |
| ១៣-លោក ខេង វេង ស៊ាង | ១៤-លោក លី ហាក់ គិមតេ |
| ១៥-លោក ខូវ ឈុន ហ៊ាង | ១៦-លោក ឃូ លាង ហាក់ |
| ១៧-លោក លុយ បានហាប់ | ១៨-លោក សៅ លាង |

# តំណាងនៅខេត្តក្នុងស្រុកបារាំង

ទីក្រុងលីយ៉ុង : លោក មឿង សុន លោក ប៊ុន សារេត

លោក សួន គិមនូ

ទីក្រុងម៉ាស៊ី : លោក ងិន ឈន

ទីក្រុងមុយលូស : លោក លាប ឡេង

ទីក្រុងណង់ស៊ី : លោក ចាន ម៉ាសារិន

## តំណាងប្រចាំអ៊ឺរុប

បារាំង : លោក ស៊ាន ម៉ាសាវ៉ាង លោក ឌី ការ៉េត

លោក ហាក់ ព្រូ លោក អ៊ូ ចល់

អង់គ្លេស : លោក ហេង ផល្លាសម្បត្តិ

ហូឡង់: លោក ផែម សុខុន

អាឡឺម៉ាញ: លោក ស៊ុយ សេងហុង

បែលហ្សិក: លោក លឿង មាន

ស្វីស: លោក សុវត្ថិ ម៉ូរ៉ា

អ៊ីតាលី: លោក ប៉ែន បូរាវុធ

អូទ្រីស: លោក កាវ សាវុធ លោក ប៊ុន សារិន

លោក ជា ដារា

## តំណាង នៅ កាណាដា

លោកស្រី សុន សានរិន លោក ស៊ាន ស៊ីត្រេក

លោក ស៊ាន កុំផ្ទេក

## តំណាង នៅ សហរដ្ឋអាមេរិក

វ៉ាស៊ីនតោន : លោក គិត សាគុន

វាស៊ីនតោនស្តេត: លោក ម៉ារិត ឆង់

ញីវយ៉ក: លោក ឈិម ស៊ីធន

ហ្វ៊ររីត: លោក ផាន់ បួយហាក់

ម៉ាសាឆ្ញូសែតៈ លោក ទិត សារុន

កាលីហ្វ័រនីៈ លោក ឃ្លោក ប៊ុនណាង លោក អ៊ុំ គុយ

លោក កែម វីសារ

អីលីណយៈ លោក ញិក និម

មីនីសូតាៈ លោក ប៊ុច សូធា លោក វ៉ាន់ប៊ុន ថង

លោក ខុង កុន លោក អ៊ឹង ប៉េង ស្រេង

លោក អុក សម្បត្តិ លោក អ៊ូ ប៉េង សាន

លោក ស៊ិន លុន លោក ឈិត យ៉ាណាត

លោក ហឿន សុភាព

អីអូវ៉រៈ លោក គង់ សមអាន

អ័ររីហ្គុងៈ លោក ចាន់ ឧស្សា

សាន់ហ្សូសេៈ លោក ឡាយ សូ លោកស្រី បេ សូផានី

លោកស្រី ទាវគិម ស៊ាត លោក បេ សារិត

លោក ហៀក សុខុម

# តំណាងនៅអូស្ត្រាលី

## ស៊ីតនី

លោក ញូង វីរុន លោក ឃាន ស៊ាន

លោក អ៊ុក សារូ លោក លី គិម ឆេង

លោកស្រី អ៊ុង ភីនី លោក អ៊ូ ប៊ុន

លោក ចិន ដេត លោក ថាច់ សេរី

លោក ពូជ រិទ្ធ លោក ហេង សូរាទ្រី

លោកស្រី កាយ ណៃរ៉ង់ លោក ចាប យូឆាន់

## មែលប៊ន

លោក គង់ ផុន លោក ពិន សារា
លោក យូហាន វ៉ាន់ឈិវ លោក ចាន់ថាវរ៉ូ
លោក ទេព ដារា លោកស្រី ពិន លន
លោកស្រី ប៉ាល់ មុន្នី លោកស្រី អ៊ុំ ដួណា
កញ្ញា តុង ចន្នី លោក ហេង សូភាទ្រី
ព្រះភិក្ខុ នន្ទ សូទេព ព្រះធម្មរក្ខិតោ លីវ ពៅ
ព្រះភិក្ខុ តែម ណារិទ្ធិ លោក ឃុន ប៊ី
លោក តុង ណាង លោក អ៊ុន យី
លោកស្រី តែ គន្ធា លោក ឃុង គិមសាន
លោក គង់ ម៉េង លោក ជឿន រតនា
លោក ង៉ែត នេរូ លោក សម ប្រីក្សា
លោកស្រី គង់ លឹមជា

## ប្រិសបាន

លោក សាយ សុខារា លោក ចាប ចាន់ថេង

## កន់បែរ៉ា

លោក សុច រាស៊ី លោក មែន ដារិន

# តំណាងនៅកម្ពុជា

លោក គង់ថាន់ ភិក្ខុ ម៉ែន សារ៉ន
លោក លេខ សុខ លោក ដាញ់ សូភាព
លោក សេង ឈីលី

លោក តាន់ ប៊ុន សូ លោក លាង គិមជ្រាន់
លោក ហេង ផលាកា លោក ញិប ពិសី
លោក ស សូជាតិ លោក ឈើង ប្រុស
លោក មាច មុំ



# លោក ស៊ាន ប៉េងសែ

បោះផ្សាយ ចែកជាសាធារណៈ ដើម្បីឱ្យ
ប្រជាពលរដ្ឋខ្មែរ បានយល់ច្បាស់ និង អាច
រក្សាការពារព្រំដែនកម្ពុជា តអង្វែងទៅ ។
ការបោះផ្សាយនេះ ត្រូវបានឧបត្ថម្ភ ពីជន
រួមជាតិទាំងឡាយ ដែលរស់នៅ ក្រៅ និង
ក្នុងប្រទេសកម្ពុជា ដែលគណៈកម្មាធិការព្រំ
ដែនកម្ពុជាសូមថ្លែងអំណរគុណ ។